**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

## ពិធីចុះហត្ថលេខាលើសារលិខិតប្តូរស្តីពីការផ្តល់ជំនួយឥតសំណងរបស់ជប៉ុន

ថ្ងៃពុធ ទី៨ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង១០:០០ព្រឹក

នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ឆ្លើយតបទៅនឹងសំណើរសុំរបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយឈរលើទស្សនៈដើម្បីជួយជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា រដ្ឋាភិបាលជប៉ុនបានសម្រេចផ្តល់ជំនួយឥតសំណងដែលមានទឹកប្រាក់សរុប បីរយសាមសិបពីរលានយ៉េន **(¥332,000,000)** ប្រមាណជាពីរលានប្រាំបួនសែនប្រាំបួនម៉ឺនដុល្លាអាមេរិក **(USD2,990,000)** ដើម្បីអនុវត្ត "កម្មវិធីអាហារូបករណ៍សម្រាប់ការអភិវឌ្ឍរបស់ជប៉ុន" (ជំនាន់ទី១៧)។

សារលិខិតប្តូរនៃគម្រោងជំនួយឥតសំណងនេះត្រូវបានចុះហត្ថលេខារវាង**ឯកឧត្តម ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង**ឯកឧត្តមគូម៉ាម៉ារូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជានៅម៉ោង១០:០០ព្រឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

ជប៉ុនបាន និងកំពុងបន្តផ្តល់ជំនួយជាអាហារូបករណ៍នេះតាំងពីឆ្នាំ២០០០មកម្លេះ។ ចាប់តាំងពីពេលនោះមក និស្សិតកម្ពុជាចំនួន៣៤៤នាក់បានចូលរួមក្នុងកម្មវិធីនេះ និងសិក្សានៅប្រទេសជប៉ុន។ ជាមួយនឹងជំនួយថ្មីនេះ និស្សិតជំនាន់ទី១៧ ចំនួន២៤នាក់នឹងទៅសិក្សានៅប្រទេសជប៉ុនចំនួនពីរឆ្នាំដែលនឹងរួមចំណែកបន្ថែមក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសកម្ពុជា។

អាហារូបករណ៍នេះផ្តល់ជូនជាពិសេសចំពោះមន្ត្រីរាជការវ័យក្មេង និងមានសមត្ថភាពដែលត្រូវបានរំពឹងថានឹងរួមចំណែកដល់ការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។ រដ្ឋាភិបាលជប៉ុនសង្ឃឹមយ៉ាងមុតមាំថានិស្សិតដែលបានបញ្ចប់ការសិក្សារួចហើយ និងនិស្សិតដែលនឹងបញ្ចប់ការសិក្សានាពេលអនាគតនឹងរួមចំណែកដល់ការអភិវឌ្ឍប្រទេសកម្ពុជា ហើយក្លាយជាស្ពានភ្ជាប់ទំនាក់ទំនងរវាងប្រទេសយើងទាំងពីរ។

---

**ស្ថានទូតជប៉ុន លេខ 194 មហាវិថីព្រះនរោត្តម ☎ (023) 217.161-4 ទូរសារ: (023) 214.330**

**អ៊ីម៉ែល: eco.jpn@pp.mofa.go.jp**

**គេហទំព័រ: www.kh.emb-japan.go.jp**